# មាតិកា

## I_ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១២-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២២៤ ស្ដីពីការតែងតាំងឯកឧត្ដមចំនួន ០៥ រូប ជាទីប្រឹក្សាឯកឧត្ដម **ខួន ញឹល** អនុប្រធានទី ១ រដ្ឋសភា នីតិកាលទី ៣ ៣២៣៩

២១-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៣៦ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្ដម និងអស់លោក ចំនួន ០៧ រូប ៣២៤០

២១-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៣៨ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះនាយទាហានជាន់ខ្ពស់ ចំនួន ៣២ រូប ៣២៤១

២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤០ ស្ដីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សប្ញទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិ ៣២៤៣

២៦-៥-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៥០៦/២៤១ ស្ដីពីការប្រោសព្រះរាជទានចំពោះ ឯកឧត្ដម **ង៉ាន លាច** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់អស្សប្ញទ្ធិ ៣២៤៤


## II_រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ


២៥-៥-២០០៦ -អនុក្រឹត្យលេខ ៤៩ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៣២៤៥

២៥-៥-២០០៦ -អនុក្រឹត្យលេខ ៥០ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៣២៤៧

២៥-៥-២០០៦ -អនុក្រឹត្យលេខ ៥១ អនក្រ.បក ស្ដីពីការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅខេត្តសៀមរាប សំរាប់ការអភិវឌ្ឍន៏ប្រព័ន្ធបង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់ ៣២៤៩

២៦-៥-២០០៦ -អនុក្រឹត្យលេខ ៥២ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ៣២៥២

២២-៥-២០០៦ -អនុក្រឹត្យលេខ ៣៥១ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៥៤

២២-៥-២០០៦ -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៥៥

២២-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៥៦

២២-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៥៧

២២-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៥៨

២២-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៥៩

២៣-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣២៦០

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣២៦២

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៥៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៦៣

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៦៤

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣២៦៥

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦២ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៦៦

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៣ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២៦៧

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៤ អនក្រ.តត ស្ដីពីការជូនមេដាយសុវត្ថារា ៣២៦៨

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៥ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣២៦៩

២៤-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៦ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣២៩៣

២៥-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៧ អនក្រ.តត ស្ដីពីការតែងតាំងក្រុមប្រឹក្សាភិបាលសំរាប់ដឹកនាំក្រុមហ៊ុន ហ្វ្រីន ត្រេដ អាណត្តិទី ៣ ៣២៩៤

២៦-៥-២០០៦ -អនុក្រឹត្យលេខ ៣៦៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣២៩៦


## ២_សេចក្ដីសំរេច


២៣-៥-២០០៦ -សេចក្ដីសំរេចលេខ ២០ សសរ ស្ដីពីការបង្កើតគណៈកម្មការគ្រប់គ្រងធនធានខ្សាច់ ៣២៩៧

២៣-៥-២០០៦ -សេចក្ដីសំរេចលេខ ២១ សសរ ស្ដីពីការបង្កើតគណៈកម្មការជំរុញការនាំចេញកសិផល ៣២៩៩


## III_ការងារបណ្ដាក្រសួង

## ១_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងការពារជាតិ


២៣-៥-២០០៦ -ប្រកាសលេខ ០២១/ប្រក/២០០៦ ស្ដីពីរូបសញ្ញាវិទ្យាស្ថាន វិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ ៣៣០១


## ២_ទីស្ដីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម


០៧-៤-២០០៦ -លិខិតលេខ ៩៩១ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេស.ធី.អិន ខនស្ត្រាក់សិន** ៣៣០៤

០៧-៤-២០០៦ -លិខិតលេខ ៩៩២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច.អិល.អ៊ី** ៣៣០៦

០៧-៤-២០០៦ -លិខិតលេខ ៩៩៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ីណូហាយដ្រូ (ខេមបូឌា) យូណាយធីត** ៣៣០៨

០៧-៤-២០០៦ -លិខិតលេខ ៩៩៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សមក្ខ អ៊ិនវេសមេន ខូ អិលធីឌី** ៣៣១០

០៧-៤-២០០៦ -លិខិតលេខ ៩៩៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អន្តរ ផ្លាយអ៊ីង សឺវីស (អេ.អេហ្វ.អេស)** ៣៣១២

១០-៤-២០០៦ -លិខិតលេខ ១០០០ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អន្តរ យៃនវើស** ៣៣១៤

១០-៤-២០០៦ -លិខិតលេខ ១០០២ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **នីអូ ឡាយហ្វ៍ ខូ អិលធីឌី** ៣៣១៦

១០-៤-២០០៦ -លិខិតលេខ ១០០៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេស៊ីតី (ខេមបូឌា) អិលធីឌី** ៣៣១៨

១០-៤-២០០៦ -លិខិតលេខ ១០០៤ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខម_តិស** ៣៣២០

១០-៤-២០០៦ -លិខិតលេខ ១០១៣ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទីហ្គើ (ខេមបូឌា) ខូ អិលធីឌី** ៣៣២២

១០-៤-២០០៦ -លិខិតលេខ ១០១៦ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **វ៉ាស៊ីង ព្រីន ខូ អិលធីឌី** ៣៣២៤

១១-៤-២០០៦ -លិខិតលេខ ១០១៧ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា នីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេម ធី ជី អេស អិម ខូ អិលធីឌី** ៣៣២៦

១១-៤-២០០៦ -លិខិតលេខ ១០១៨ ពណ.នតក ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភាបូន យ៉ាំងហ្គល ឌីវេឡុបមេន (ខេមបូឌា) លីមីធីត** ៣៣២៨

១១-៤-២០០៦ -លិខិតលេខ ១០១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អង្គរ (ខេមបូឌា) អិនធើណេសិនណាល** ៣៣៣០

១១-៤-២០០៦ -លិខិតលេខ ១០២០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជី ជេយ ព្រីសឃើ អេឃើឌីមី (ខេមបូឌា) ខមភេនី អិលធីឌី** ៣៣៣២

១១-៤-២០០៦ -លិខិតលេខ ១០២១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភូវ៉ា អ៊ិនវេសមេន អិនធើណេសិនណាល (ខេមបូឌា)** ៣៣៣៤

១១-៤-២០០៦ -លិខិតលេខ ១០២៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ូវ ហ្វីសហ៊ុត** ៣៣៣៦

១១-៤-២០០៦ -លិខិតលេខ ១០២៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហុងលូម៉េន (ខេមបូឌា) វើលដ៏គ្រុប** ៣៣៣៨

១១-៤-២០០៦ -លិខិតលេខ ១០២៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថូល (ខេមបូឌា)** ៣៣៤០

១១-៤-២០០៦ -លិខិតលេខ ១០២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អង្គរ ណូវែស្ទេន ណូនី ធី ខូ អិលធីឌី** ៣៣៤២

១១-៤-២០០៦ -លិខិតលេខ ១០២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **លីប៊ីធី ម៉ាញូនីខ អិនធើណេសិនណាល (ខេមបូឌា) លីមីធី** ៣៣៤៤

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភា លើកទី ៤ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់ឯកឧត្តមប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងជាទីប្រឹក្សាឯកឧត្តម ងួន ញ៉ិល អនុប្រធានទី១ រដ្ឋសភា នីតិកាលទី៣ :

១- ឯកឧត្តម ជា អឿង ជាទីប្រឹក្សា មានឋានៈស្មើ រដ្ឋលេខាធិការ ។
២- ឯកឧត្តម ឆួច សែ ជាទីប្រឹក្សា មានឋានៈស្មើ រដ្ឋលេខាធិការ ។
៣- ឯកឧត្តម គង់ ឌីឡា ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។
៤- ឯកឧត្តម ម៉ួន ធី ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។
៥- ឯកឧត្តម ឡួង សារ៉ាវី ជាទីប្រឹក្សា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៧៤-០៦០៥-២៣៨

លេខៈ ២៣០ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាំ ឥ តាន់**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៦*

នស/រកត/០៥០៦/២៣៦

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :
១-ឯកឧត្តម សម សុគ្គា
២-ឯកឧត្តម ទឹម សោភ័ណ
៣-ឯកឧត្តម សែម សុវណ្ណនី

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :
-ឯកឧត្តម ហេង រតនា

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ចំពោះ :
១-ឯកឧត្តម ទ៊ុក ផេង
២-ឯកឧត្តម ឡេង សុជា
៣-លោក នេត សុផល

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ-ល-០៦០៥.២៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៦

លេខ: ២៣៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២៣៨

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រតនខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

( បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា )

## ប្រោសព្រះរាជទាន

-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា**

១-ឯកឧត្តម ឧត្តមសេនីយ៍ត្រី ឈឿន ចាន់ថន អត្តលេខ ០០៣៣៦១ ជំនួយការផ្ទាល់សម្តេចប្រធានព្រឹទ្ធសភា និងជាមេបញ្ជាការអង្គរក្សសម្តេចប្រធានព្រឹទ្ធសភា ។

-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ**

| | | | |
|---|---|---|---|
| ២-ឯកឧត្តម | ឆាន់ វឌ្ឍនៈ | | |
| ៣-ឧត្តមសេនីយ៍ត្រី | ឡាវ វ៉ាន់ | អត្តលេខ | ០០៣៣៨៥ |

-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា**

| | | | |
|---|---|---|---|
| ៤-ឧត្តមសេនីយ៍ត្រី | អ៊ឹង សំកត់ | អត្តលេខ | ០០១២៤១ |
| ៥-ឧត្តមសេនីយ៍ត្រី | គីម សោភ័ណ្ឌ | អត្តលេខ | ០០១២៣៧ |
| ៦-ឧត្តមសេនីយ៍ត្រី | យូ សិរីវុឌ្ឍ | អត្តលេខ | ០១៩៧០៣ |
| ៧-ឧត្តមសេនីយ៍ត្រី | ស ថាវី | អត្តលេខ | ០០១៥០០ |
| ៨-ឧត្តមសេនីយ៍ត្រី | ឡាក់ សុគន្ធាវុធ | អត្តលេខ | ០១១០០១ |

- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ**

| | | | |
|---|---|---|---|
| ៩-វរសេនីយ៍ឯក | ឡី ណាវី | អត្តលេខ | ០០១៦០៧ |
| ១០-វរសេនីយ៍ឯក | យស់ សុខា | អត្តលេខ | ០០៤១០២ |
| ១១-វរសេនីយ៍ឯក | ញ៉ែម មុន្នីនាថ | អត្តលេខ | ០១១០១៩ |

| | | | |
|---|---|---|---|
| ១២-វរសេនីយ៍ឯក | បៀន ឡេង | អត្តលេខ | ០០៤១០០ |
| ១៣-វរសេនីយ៍ឯក | ពោជ សាម៉ន | អត្តលេខ | ០០៣៣៥៦ |
| ១៤-វរសេនីយ៍ឯក | នួន សុខ័ណ្ណរ៉ា | អត្តលេខ | ០១០៩៩៧ |
| ១៥-វរសេនីយ៍ឯក | ជុំ សោភ័ណ្ឌ | អត្តលេខ | ០១០៩៨៥ |
| ១៦-វរសេនីយ៍ឯក | សាន់ ប៊ុនណា | អត្តលេខ | ០០៤១០៣ |
| ១៧-វរសេនីយ៍ឯក | ចេង ហុង | អត្តលេខ | ០១៩៧១០ |
| ១៨-វរសេនីយ៍ឯក | ងិន ធឿន | អត្តលេខ | ០០២៣១៩ |
| ១៩-វរសេនីយ៍ឯក | ឈុន វឌ្ឍនះ | អត្តលេខ | ០០៣៣៦៦ |
| ២០-វរសេនីយ៍ឯក | តូច វ៉ាសនា | អត្តលេខ | ០០២៣៣៩ |
| ២១-វរសេនីយ៍ឯក | យ៉ន វ៉ាយ៉េត | អត្តលេខ | ០០៣៣៦២ |
| ២២-វរសេនីយ៍ឯក | ញ៉ែម ចំណាន | អត្តលេខ | ០០៤១០៦ |
| ២៣-វរសេនីយ៍ឯក | សុខ សារ៉ន | អត្តលេខ | ០០៤០៩៦ |
| ២៤-វរសេនីយ៍ឯក | ពៅ ឌីណា | អត្តលេខ | ០០៤០៩៨ |
| ២៥-វរសេនីយ៍ឯក | សោម វិចិត្រ | អត្តលេខ | ០១១០១១ |
| ២៦-វរសេនីយ៍ឯក | គីម សារី | អត្តលេខ | ០១០៩៨៦ |
| ២៧-វរសេនីយ៍ឯក | សន ម៉េងសាវុធ | អត្តលេខ | ០០៣៣៧០ |
| ២៨-វរសេនីយ៍ឯក | វង្ស ចាន់ប៉ាញ | អត្តលេខ | ០១១០១៥ |
| ២៩-វរសេនីយ៍ឯក | កែវ សូដានី | អត្តលេខ | ០១៩៦៩៦ |
| ៣០-វរសេនីយ៍ឯក | ប៉ុល ខុន | អត្តលេខ | ០១៩៦៩៩ |
| ៣១-វរសេនីយ៍ឯក | ជា ថា | អត្តលេខ | ០១២៧៥៣ |
| ៣២-វរសេនីយ៍ឯក | ទឹម សម្បត្តិ | អត្តលេខ | ០៥៦១៨៦ |

**ព្រះហស្តលេខា និងព្រះរាជលញ្ចករ**
**នរោត្តម សីហមុនី**

*ជ.ស.ម-០៥០៥.៣៤៩*

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី៥១ ខែ ឧសភា ឆ្នាំ ២០០៦

លេខៈ ២២៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សាន់ តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/៧៤០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបានទទួលការប្រោសប្រទាននូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ ជូនមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ ចំនួន ០៥ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើ ជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

១- លោក ឱុច សារុន
២- លោក សត្យា ខុធ
៣- លោក សុខ ម៉ន
៤- លោក សេង គុង
៥- លោក ប៉ែន សំបូរ

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តន៍ឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ជករ**
**នរោត្តម សីហមុនី**

លេខៈ៧៣៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ,ថ្ងៃទី ... ខែ... ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សារ៉ាវី តាន់**

ពរល.០៦០៥.៧៥៦

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៦

៤២៨

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៦/២៤១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

**ប្រោសព្រះរាជទាន**

ចំពោះ

ឯកឧត្តម **ឃ៉ាន លាច**

នូវ

**គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣កស.០៦០៥.២៥២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០០៦

លេខៈ ៣៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភាឆ្នាំ២០០៦
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាអ៊ី តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

...រដ្ឋាភិបាលកម្ពុជា

...ខ : ៤៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្ដីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្ដីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្ដីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្ដីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៣.២៤០ លានរៀល (បីពាន់ពីររយសែសិបលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ជូន ក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់បំណុលថ្លៃផ្គត់ផ្គង់ទំនិញឯកសណ្ឋាន សញ្ញាសក្តិ សំភារៈបន្ទាប់បន្សំ ឆ្នាំ ២០០២ និង ២០០៣ ជូនក្រុមហ៊ុន **សោម សុផល** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ជរដ្ឋាភិបាលកម្ពុជា

ខ : ៥០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ .ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ . ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥៩ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦.៩៣០ លានរៀល (ប្រាំមួយពាន់ប្រាំបួនរយសាមសិបលានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១០ (បៀវត្ស និង ប្រាក់បំណាច់) ជូនក្រសួងការពារជាតិ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់បំណុលថ្លៃផ្គត់ផ្គង់អង្ករបប ក្នុងឆ្នាំ ២០០៣ ជូនក្រុមហ៊ុន **ម៉ែន សារុន** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ :...៥១...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការធ្វើចំណាត់ថ្នាក់ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ បរិវេណដីនៅខេត្តសៀមរាប សំរាប់ការអភិវឌ្ឍន៍ប្រពន្ធ័បង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខៈ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ : នស/ រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញព្រះរាជក្រមលេខ : នស/រកម/០៨០១/១២ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ : ០៤ អនក្រ. បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ប្រកាសលេខ ១៥១ សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៤
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**មាត្រា ១ .-**

ត្រូវបានកំណត់បរិវេណដី សំរាប់ធ្វើការអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់ ដែលមានទីតាំងស្ថិតនៅ ភូមិថ្មី ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

**មាត្រា ២ .-**

ត្រូវបានធ្វើចំណាត់ថ្នាក់បរិវេណដី ដូចមានបញ្ជាក់ក្នុងប្លង់ឧបសម្ព័ន្ធ ដែលមានផ្ទៃក្រឡាសរុប ២៥ ហិកតា ជាប្រភេទដីមានលក្ខណៈសម្បត្តិជាទ្រព្យសាធារណៈរបស់រដ្ឋ ដែលមានទីតាំងស្ថិតនៅ ភូមិថ្មី ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ប្រកបដោយរបបគតិយុត្ត ដូចមានចែងក្នុងមាត្រា ១៥, មាត្រា ១៦, មាត្រា ១៧ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ដើម្បីសម្រេចនូវគម្រោងនេះ និងមាននិយាមការ ដូចខាងក្រោម÷

| | |
|---|---|
| E= 374408-N=1474758, | E = 373807 - N = 1474435, |
| E= 374493-N=1474068, | E =374401 - N=1473521, |
| E= 374367-N=1473523, | E =374348 - N=1473373, |
| E= 374274-N=1473376, | E = 374171- N=1473294, |
| E= 373251-N=1473604, | E =373431 - N=1474493, |
| E= 373642-N=1474460, | E =374402 - N=1474869. |

**មាត្រា ៣ .-**

រាល់ការទន្ទ្រានយកដី ការដោះដូរ ការទិញលក់ ឬការផ្ទេរកម្មសិទ្ធិ ការចេញប័ណ្ណសំគាល់សិទ្ធិកាន់កាប់នៃអចលនៈវត្ថុទាំងឡាយ តាមគ្រប់រូបភាពទាំងអស់ ទោះស្របច្បាប់ក៏ដោយ ដែលស្ថិតក្នុងបរិវេណដីបង្កកដូចបានពណ៌នាខាងលើនេះ និងការចេញលិខិតអនុញ្ញាតឱ្យសាងសង់សំណង់ថ្មី ត្រូវបានហាមឃាត់ លើកលែងតែការផ្ទេរកម្មសិទ្ធិជាផលប្រយោជន៍សាធារណៈ ។

រាល់ការបំពានលើបទប្បញ្ញត្តិ ដូចមានចែងខាងលើ អ្នកប្រព្រឹត្តល្មើសនឹងទទួលទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា ២៥៩ នៃច្បាប់ភូមិបាល ចុះថ្ងៃទី ៣១ សីហា ឆ្នាំ ២០០១ ។

**មាត្រា ៤ .-**

ម្ចាស់កម្មសិទ្ធិ ឬភោគីនៃឡូត៍ដី ក្នុងបរិវេណដែលនឹងត្រូវផ្ទេរកម្មសិទ្ធិ ឬភោគៈមកប្រគល់ឱ្យរដ្ឋ នឹងទទួលបាននូវការទូទាត់សំណង ក្រោមកិច្ចការអង្កេត និងការឯកភាពលើសំណើសំណង ស្នើឡើងដោយគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ដោយសារគំរោងការអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរទឹកកខ្វក់ និងសំរាប់សាងសង់ស្ថានីយ៍ចំរោះទឹកកខ្វក់ខាងលើនេះ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ , ក្រសួងសាធារណការ និងដឹកជញ្ជូន , ក្រសួងទេសចរណ៍ និង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការទាំងអស់ ដែលមានការពាក់ព័ន្ធ ព្រមទាំងអភិបាលខេត្តសៀមរាប ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៦ .-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

ភ្នំពេញ ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី សូមហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**គាត ឈន់**

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥២៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.០០០ លានរៀល (មួយពាន់លានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ជូនក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីទូទាត់បំណុលលើការផ្គត់ផ្គង់ឯកសណ្ឋាន សញ្ញាសក្តិ និង សំភារៈបន្ទាប់បន្សំ ជូនកងកំលាំងនគរបាលជាតិ ក្នុងឆ្នាំ ២០០៣ ជូនក្រុមហ៊ុន **ណារី ហ្វាម៉ិន** ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៣៥៦ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ប្រគេនព្រះតេជគុណ **ហេង សំបុរ** ព្រះមេគណខេត្ត កោះកុង ដែលមានស្នាព្រះហស្ត និងគុណបំណាច់ធំៗជាច្រើន ក្នុងការជួយអភិវឌ្ឍន៍វិស័យព្រះពុទ្ធសាសនា និងសង្គមជាតិ ដោយបានបរិច្ចាគបច្ច័យ ចូលរួមកសាងអគារសិក្សា សាលាឆាន់ ព្រះវិហារ កុដិ និង សមិទ្ធផលផ្សេងៗទៀត នៅក្នុង *វត្តជោតញ្ញាណ* ឃុំស្មាច់មានជ័យ និង *វត្តកោះស្រឡៅ* ឃុំកោះកាពិ ស្រុកកោះកុង ខេត្តកោះកុង អស់បច្ច័យចំនួន ១៧០.៦៧៣ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលខេត្តកោះកុង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ✓

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៥៤ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ចំនួន០៧គ្រឿង ប្រគេន និង ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានបរិច្ចាគបច្ច័យ និងថវិកាចូលរួមជួយកសាងព្រះវិហារ ផ្លូវថ្នល់ ស្ពាន ស្រះទឹក របង ខ្លោងទ្វារ កុដិ និងសមិទ្ធផលផ្សេងៗទៀត នៅក្នុងពុទ្ធសីមាវត្តដំណាក់ត្រាច ឃុំដំបូករ៉ូង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **កែវ ចន្ថា** អនុគណស្រុកភ្នំស្រួច បច្ច័យចំនួន ១២៣.៨១៨.៧៥ ដុល្លារ
២-លោក **តាំង ផេងឆៃ** ទីប្រឹក្សាផ្ទាល់សម្តេចព្រះសង្ឃរាជគណៈមហានិកាយ ឧបត្ថម្ភថវិកា ចំនួន ១០.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោកស្រី **ឃុន ណៃ** ថវិកា ចំនួន ៥.០០០ ដុល្លារ
២-ឧត្តមសេនីយ៍ត្រី **ស្រ៊ុន សារឿន** ថវិកា ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-វរសេនីយ៍ឯក **ឌុន ណម** ថវិកា ចំនួន ៤.០០០ ដុល្លារ
២-វរសេនីយ៍ទោ **ឡាយ លីមស្រួយ** នាយការិយាល័យហ្វឹកហ្វឺន យុទ្ធភូមិភាគទី៣ ឧបត្ថម្ភថវិកា ចំនួន ៣.០០០ ដុល្លារ
៣-លោក **មួង ឡាង** មេឃុំដំបូករូង ថវិកា ចំនួន ២.០០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និងអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ ✓

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៣៥៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និង ជូនសប្បុរសជន ចំនួន០៥រូប ដែលបានចំណាយធនធានចូលរួមជួយកសាង កុដិ ០១ខ្នង បណ្តោយ១៧ម៉ែត្រ ទទឹង១០ម៉ែត្រ សំរាប់ព្រះសង្ឃ សមណសិស្ស និស្សិត និមន្តមកពីបណ្តាខេត្ត-ក្រុង ដើម្បីគង់ស្នាក់នៅបន្តរៀនសូត្រ ស្ថិតនៅក្នុងពុទ្ធសីមា *វត្តបទុមវតី* សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដូចមាន រាយព្រះនាម និងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

-ព្រះតេជគុណ ចៅ សាន បច្ច័យ ចំនួន ១៦.០០០ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ព្រះតេជគុណ ញ៉ាន ថាញ់ បច្ច័យ ចំនួន ៥.៦០០ ដុល្លារ

២-លោក អ៊ូរ ដារា ថវិកា ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរិទ្ធស្ថាបនាជាតិ :**

១-ព្រះតេជគុណ ថង សុមេធ បច្ច័យ ចំនួន ២.៥០០ ដុល្លារ

២-លោក គីម សឿន ថវិកា ចំនួន ២.២០០ ដុល្លារ

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៤៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផល នៅក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-ឧកញ៉ា **លី យ៉ុងផាត់** នាយកក្រុមហ៊ុន DUTY FREE SHOP បានជួយជួសជុលផ្លូវ លេខ ៦៨ ពីព្រំប្រទល់អូរស្មាច់ ឃុំអូរស្មាច់ ដល់ភូមិច្រេស ឃុំសំរោង និងកសាងផ្លូវភ្ជោះ ក្រាលកៅស៊ូ ពីរង្វង់មូលទីរួមខេត្ត ដល់សាលាខេត្ត ចំណាយអស់ថវិកា ចំនួន ៥៨៧.៥០០ បាត និង ចំនួន ១១.៨០០ ដុល្លារ ។

២-លោក **អ៊ឹន គួន** នាយកក្រុមហ៊ុន KPLP CONSTRUCTION Co,.LTD បានជួយជួសជុលផ្លូវ លេខ ៦៨ ពីព្រំប្រទល់អូរស្មាច់ ឃុំអូរស្មាច់ ដល់ភូមិច្រេស ឃុំសំរោង ចំណាយអស់ថវិកា ចំនួន ៥៨៧.៥០០ បាត ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។៸៴

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៣៥៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២រូប ដែលបានផ្ដល់ថវិកាជួយកសាងអគារសិក្សា ០២ខ្នង នៅអនុវិទ្យាល័យ តាជូ ០១ខ្នង មាន០៦បន្ទប់ និង នៅអនុវិទ្យាល័យ ផ្គាំ ០១ខ្នង មាន០៣បន្ទប់ បំពាក់ដោយ តុ កៅអីសិស្សគ្រប់គ្រាន់ និងសមិទ្ធផលមួយចំនួនទៀត នៅឃុំផ្គាំ និងឃុំតាជូ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម :-

១-លោក **ម៉ាតាំង ម៉ុងឌីយ៉ោ** ( MARTIN MAINDIAUX ) ប្រធានអង្គការកុមារមេគង្គប្រចាំព្រះរាជាណាចក្រកម្ពុជានិងប្រចាំខេត្តបន្ទាយមានជ័យ បានផ្ដល់ថវិកា ចំនួន ៣៤.០៦០.៥៨ ដុល្លារ ។

២-លោក **ហ្វ្រង់ស្វា ហ្វូកា** ( FRANCOIS FOUCART ) ប្រធានអង្គការកុមារមេគង្គប្រចាំអឺរ៉ុប និងអាស៊ីអាគ្នេយ៍ បានផ្ដល់ថវិកា ចំនួន ១៥.៩៦៤.២៩ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៥៦ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៧រូប ដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគបច្ច័យ និង ថវិកា ចូលរួមជួយកសាងព្រះវិហារ កុដិ និងខ្លោងទ្វារ នៅក្នុងពុទ្ធសីមា *វត្តម្រោមដូនចាស់* ឃុំម្រោម ស្រុករមាសហែក ខេត្តស្វាយរៀង ដូចមានរាយព្រះនាមនិងនាមខាងក្រោមៈ-

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះគ្រូធម្មនាថមុនី **ឆេព កុសល** | | បច្ច័យ ចំនួន ១២.០០០ ដុល្លារ |
| ២-អ្នកស្រី **សឹន ស្រីស៊ុណាន** និង បុត្រ | | ថវិកា ចំនួន ១០.១៥០ ដុល្លារ |

**ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

| | | |
|---|---|---|
| ១-ព្រះតេជគុណ **យិន សុខ** | ចៅអធិការ | បច្ច័យ ចំនួន ៤.៣៥០ ដុល្លារ |
| ២-ព្រះតេជគុណ **ឆេង សុវណ្ណ** | ចៅអធិការ | បច្ច័យ ចំនួន ៣.៦០០ ដុល្លារ |
| ៣-លោក **មាស សុខុម** និង ភរិយា | សប្បុរសជន | ថវិកា ចំនួន ៤.២៥០ ដុល្លារ |
| ៤-លោក **ហ៊ឹម ផាន់** និង ភរិយា | សប្បុរសជន | ថវិកា ចំនួន ៤.២០០ ដុល្លារ |
| ៥-លោក **ហ៊ឹម មុន្នី** និង ភរិយា | សប្បុរសជន | ថវិកា ចំនួន ២.០៤៥ ដុល្លារ |

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៦
នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៥៧ អនុក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៧ / ០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយច្បាប់ ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពី ការបង្កើតក្រុមប្រឹក្សានីតិកម្ម និងនាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ចំណុះក្រសួងមហាផ្ទៃ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់ភារកិច្ច ជូនមន្ត្រីរាជការ ចំនួន ១០ រូប ក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោក វរសេនីយ៍ឯក **តុល គីមលី** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន

២- លោកវរសេនីយ៍ឯក **ហ៊ូ សេងលន់** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន

៣- លោកវរសេនីយ៍ឯក **ប៊ុរីសាន ជីឡូប៉េស** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន

៤- លោកវរសេនីយ៍ឯក **លីម ងៀន** ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន

| | |
|---|---|
| ៥- លោកវរសេនីយ៍ទោ **ប្រូក ម៉ៃខុត្តម** | ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន |
| ៦- លោកអនុសេនីយ៍ត្រី **ហួន ចំនួកក្តុជា** | ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន |
| ៧- លោក **ហ៊ិន យុទនា** | ឋានន្តរសក្តិ អនុមន្ត្រីថ្នាក់លេខ ១១ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន |
| ៨- លោក **មុនី ទីរៈ** | ឋានន្តរសក្តិ អនុមន្ត្រីថ្នាក់លេខ ១៣ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន |
| ៩- លោក **សូរ ឌីម៉ា** | ឋានន្តរសក្តិ អនុមន្ត្រីថ្នាក់លេខ ១៣ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន |
| ១០- លោក **វៀល សុភិន** | ឋានន្តរសក្តិ លេខាធិការរដ្ឋបាល ប្រភេទ គ៣-១២ ជាសមាជិកក្រុមប្រឹក្សានីតិកម្ម មានឋានៈស្មើប្រធាននាយកដ្ឋាន ។ |

**ប្រការ ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣ :** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  ( ដើម្បីជូនជ្រាប )
- ដូចមាត្រា ៣ ( ដើម្បីអនុវត្ត )
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៣៥៨ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

~~~~~~~~~

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញព្រះរាជក្រមលេខ ជស / រកម / ០៦៩៦ / ០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក. ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅ នៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក. ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតទូរគមនាគមន៍កម្ពុជា ជាសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ស ម្រេ ច

**មាត្រា១ :** តែងតាំងលោក **ឡាយ ម៉ារីរ៉ូ** បច្ចុប្បន្នអគ្គនាយករងរដ្ឋបាលក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាអគ្គនាយកក្រុមហ៊ុន Camintel ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចខែងក្នុងមាត្រា ៣
  ឯកសារ-កាលប្បវត្តិ
~~~~~~~~~

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: [illegible]

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

## សម្រេច

**មាត្រា១:** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **Odile HANROT** អគ្គលេខាធិការអង្គការ **Enfants d'Asie ASPECA ( E.A.A)** នៅទីក្រុង **Paris** ដែលបានជួយសាងសង់អគារមួយខ្នង មាន០៥ បន្ទប់ នៅបូរីនិស្សិតរបស់អង្គការកុមារអាស៊ីអាស្ពេកា ចំណាយអស់ទឹកប្រាក់ចំនួន ២៨.៤៩៨ ដុល្លារ ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៣៦០...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

## សម្រេច

**មាត្រា១៖** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោកស្រី **Odile HANROT** អគ្គលេខាធិការ អង្គការ **Enfants d'Asie ASPECA ( E.A.A)** នៅទីក្រុង **Paris** ដែលបានជួយឧបត្ថម្ភ ដល់បូរីកុមារកំព្រា ខេត្តមណ្ឌលគិរី តាំងពីឆ្នាំ ១៩៩៧ រហូតមកដល់បច្ចុប្បន្ន ព្រមទាំងជួយសាងសង់ផ្ទះស្នាក់នៅរបស់កុមារចំនួន០៦ខ្នង ចំណាយអស់ទឹកប្រាក់ចំនួន ៨៥.៣៩០ដុល្លារ ។

**មាត្រា២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣៦១...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

## សម្រេច

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយសំរិទ្ធការងារ** ជូនលោកស្រី **អ៊ុត សឿន** ប្រធានការិយាល័យសុខុមាលភាពកុមារនៃមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តមណ្ឌលគីរី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិកន្លងមក ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៈ**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ.....៣៦៤.....អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

៙

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា

**សម្រេច**

**មាត្រា១ៈ** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនលោក **ឌួង សារុល** ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តមណ្ឌលគីរី ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិ មាតុភូមិកន្លងមក ។

**មាត្រា២ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល ៈ**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
